អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ០៧២_សណ.១៧អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ, ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

# លិខិតអនុញ្ញាត

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រម លេខនស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- អនុវត្តតាមការកំណត់របស់អនុក្រឹត្យ លេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- អាជ្ញាបណ្ណរួមលេខ៣៦៣.អ ចេញឲ្យលោក លាង ផល្លា នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣
- យោងសេចក្តីសម្រេចស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនី តាមយន្តការកែតម្រូវថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូតរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ៣៨២.សរ-១៥-អអក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥
- យោងតាមតម្លៃប្រេងម៉ាស៊ូតលើទីផ្សារ ក្នុងខែមករា ឆ្នាំ២០១៧
- យោងតាមចំណារឯកភាពលើកំណត់បង្ហាញរបស់នាយកដ្ឋានបញ្ជីថ្លៃលក់ និងត្រួតពិនិត្យគណនេយ្យសេវាកម្ម លេខ០០៦-១៧-បថល ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧

## អនុញ្ញាត

**ប្រការ ១ -**

ផ្អែកតាមតារាងថ្លៃលក់អគ្គិសនីនៅក្នុងប្រការ១ នៃសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ៣៨២.សរ-១៥-អអក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ និងផ្អែកលើមូលដ្ឋានថ្លៃប្រេងម៉ាស៊ូតនៅលើទីផ្សារជាមធ្យម នៅក្នុងខែមករា ឆ្នាំ២០១៧ មានតម្លៃស្មើនឹង ៧២៤ (ប្រាំពីររយម្ភៃបួន)ដុល្លារអាមេរិកក្នុង១តោន អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចអនុញ្ញាតឲ្យសេវាករ លាង ផល្លា អ្នកកាន់អាជ្ញាបណ្ណលេខ៣៦៣.អ ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ទូទៅ នៅឃុំកោះសូទិន ស្រុកកោះសូទិន និងឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម អនុវត្តអត្រាថ្លៃលក់ស្មើនឹង ២,៥០០ (ពីរពាន់ប្រាំរយ) រៀលក្នុង១គីឡូវ៉ាត់ម៉ោង ។

**ប្រការ ២ -**

អត្រាថ្លៃលក់អគ្គិសនីថ្មីខាងលើនេះ ត្រូវបានអនុញ្ញាតឲ្យអនុវត្តចំពោះការចេញ"វិក្កយបត្រថ្លៃអគ្គិសនី" ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ តទៅ រហូតដល់មានការអនុញ្ញាតជាថ្មីដោយអាជ្ញាធរអគ្គិសនីកម្ពុជា ទៅតាមកម្រិតថ្លៃប្រេងម៉ាស៊ូតលើទីផ្សារ។ អ្នកកាន់អាជ្ញាបណ្ណមិនត្រូវផ្លាស់ប្តូរខួប និងពេលវេលាក្នុងការកត់ត្រាលេខអំណាននាឡិកាស្ទង់ កាលបរិច្ឆេទនៃការចេញវិក្កយបត្រថ្លៃអគ្គិសនី និងការបែងចែកក្រុមអតិថិជនទេ ក្នុងការអនុវត្តអត្រាថ្លៃលក់អគ្គិសនីថ្មីខាងលើ។ បញ្ជីថ្លៃលក់អគ្គិសនីចាស់ដែលបានដាក់ឲ្យប្រើប្រាស់ត្រូវចាត់ទុកជានិរាករណ៍ ចាប់ពីពេលអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ ។

**ប្រការ ៣ -**

ការអនុវត្តអត្រាថ្លៃលក់អគ្គិសនីនេះ មានប្រសិទ្ធភាពអនុវត្តចំពោះអ្នកប្រើប្រាស់អគ្គិសនីដែលឋិតនៅក្នុងតំបន់ចែកចាយរបស់សេវាករ លាង ផល្លា ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ ទូទៅ នៅឃុំកោះសូទិន ស្រុកកោះសូទិន និងឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាមប៉ុណ្ណោះ ។

**ប្រការ ៤ -**

សេវាករ លាង ផល្លា មានភារកិច្ចផ្សព្វផ្សាយអំពីការអនុញ្ញាតនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទដែលពាក់ព័ន្ធ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

ចម្លងជូន:
- ក្រសួង រ៉ែ និងថាមពល
- សាលាខេត្តកំពង់ចាម
- មន្ទីរ រ៉ែ និងថាមពល ខេត្តកំពង់ចាម
- សាលាស្រុកកំពង់សៀម
- សាលាស្រុកកោះសូទិន
- សាលាឃុំកោះសូទិន - សាលាឃុំកោះមិត្ត
  "ដើម្បីជូនជ្រាប"
- សេវាករ លាង ផល្លា
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ